ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០១៩ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ បឹងថ្កាស់

ភូមិ ៖ បាធាយ ជ្រែក ស្រះព្រីង អូម៉ាល់ ទួល ស្វាយពក ជាលា បែកពាង

ឃុំ ៖ បាធាយ និងជាលា

ស្រុក ៖ បាធាយ

ខេត្ត ៖ កំពង់ចាម

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០១៩ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ បឹងថ្កាស់

ភូមិ ៖ បាធាយ ជ្រែក ស្រះព្រីង អូម៉ាល់ ទួល ស្វាយពក ជាលា បែកពាង

ឃុំ ៖ បាធាយ និងជាលា

ស្រុក ៖ បាធាយ

ខេត្ត ៖ កំពង់ចាម

# មាតិកា

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១. ស្ថានភាពទូទៅ** ........ 1

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........ 1

ក- ប្រជាសាស្ត្រ ........ 1

ខ- មុខរបរ ........ 2

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ 2

ក- ទីតាំង ........ 2

ខ- ដែននេសាទ ........ 3

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ 3

ឃ- ធនធានជលផល ........ 3

**៤. ការធ្វើនេសាទ** ........ 3

ក- អ្នកនេសាទ ........ 3

ខ- ឧបករណ៍នេសាទ ........ 4

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ ........ 5

**៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ** ........ 5

ក- ទស្សនៈវិស័យ ........ 5

ខ- គោលបំណង ........ 5

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ 6

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ 6

គ២-ផែនការបោះបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍ ........ 8

គ៣-ផែនការកែលំអដែននេសាទ ........ 8

គ៤-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ 8

គ៥-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ........ 9

គ៦-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ 9

គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ........ 10

គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ 11

ឃ- ផែនការយុទ្ធសាស្ត្រ ........ 12

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងថ្លាស់ រយៈពេល ៣ឆ្នាំ** (២០១៩ដល់២០២១) ........ 13

**តារាងកម្មវិធីការងារ** ........ 16

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទបឹងថ្កាស់បានរៀបចំមហាសន្និបាតកំណើតលើកដំបូង នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០៧ មានសមាជិកសហគមន៍នេសាទសរុបចំនួន២០៧នាក់ មានប្រុសចំនួន២០២ និងស្រីចំនួន០៥នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន២០៧គ្រួសារ មានគណៈកម្មការសហព័ន្ធសហគមន៍នេសាទចំនួន០៥នាក់ ស្រីគ្មាន និងមានក្រុមល្បាតចំនួន០៨នាក់ចែកជា២ក្រុម ហើយនិងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨។ បន្ទាប់មក បានរៀបចំមហាសន្និបាតលើកទី២ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដើម្បីបោះឆ្នោតជ្រើសរើសគណកម្មការសហគមន៍នេសាទ អាណត្តិថ្មី គឺបានគណៈកម្មការសហគមន៍នេសាទចំនួន១១នាក់ ស្រី១នាក់។

សហគមន៍នេសាទបឹងថ្កាស់មានទីតាំងស្ថិតនៅក្នុងភូមិបាធាយ ជ្រែក ស្រះព្រីង អូម៉ាល់ ទួល ស្វាយពក ឃុំបាធាយ និងភូមិជាលា បែកពាង ឃុំជាលា ខេត្តកំពង់ចាម។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- រៀបចំធ្វើមហាសន្និបាតបង្កើតសហគមន៍នេសាទ
- រៀបចំរចនាសម្ពន្ធគណៈកម្មការសហគមន៍នេសាទ និងបង្កើតក្រុមល្បាត
- រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- កំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍
- រៀបចំធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- បង្កើតកន្លែងអភិរក្សត្រីមេពូជនៅក្នុងបឹងឃ្លួយ
- ចុះល្បាត តាមដាន និងទប់ស្កាត់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍
- ស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណកម្មការសហគមន៍នេសាទ
- ចូលរួមប្រជុំជាមួយអាជ្ញាធររដ្ឋបាលភូមិ ឃុំ
- ប្រមូលព័ត៌មានទូទៅសម្រាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ២. អំពីប្រជាសាស្រ្ត និងសេដ្ឋកិច្ចសង្គម

ក- ប្រជាសាស្រ្ត

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទ១៦៩៧៨នាក់ ប្រុស៨៥៨០នាក់ ស្រី៨៣៩៨នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន១៦៩៧៣នាក់ ខ្មែរឥស្លាម០៤នាក់ និងអាណិកជនវៀតណាម០១នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន៦២៧នាក់
- ចំនួនពោះម៉ាយក្នុងសហគមន៍នេសាទមាន១២៩នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១២៩នាក់ ស្រី៦៤នាក់

- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន២០៦នាក់ ស្រី១៥៧នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន៤៩នាក់ ស្រី២៨នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ មានអ្នកកាន់សាសនាព្រះពុទ្ធ៩៩,៩៨%។ ក្រៅពីនេះ អ្នកកាន់សាសនាអ៊ីស្លាម០,០២% សាសនាកាតុលិក០%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៤២១នាក់ ស្រី២៣៩នាក់ កម្រិតថ្នាក់បឋមសិក្សាមានចំនួន៤៤០៧នាក់ ស្រី១៨៩៩នាក់ និងកម្រិតមធ្យមសិក្សាចំនួន២៤៤៤នាក់ ស្រី១៣៧៥នាក់ និងកម្រិតថ្នាក់ឧត្តមសិក្សាចំនួន២៦៧នាក់ ស្រី១២៩នាក់ ។

ខ- មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

| | |
|---|---|
| - ធ្វើនេសាទចំនួន | ៩៣គ្រួសារ |
| - ធ្វើស្រែចំនួន | ៣០៣២គ្រួសារ ទំហំផ្ទៃដី៥៦៣៦ហិកតា |
| - ធ្វើវារីវប្បកម្មចំនួន | ២២គ្រួសារ ចំនួន១៨ហិកតា |
| - ជាងផ្ទះចំនួន | ៩៩គ្រួសារ |
| - ធ្វើចំការចំនួន | ១២៧ |
| - ចិញ្ចឹមសត្វចំនួន | ៩៥គ្រួសារ |
| - លក់ដូរចំនួន | ១៥៨គ្រួសារ |
| - កម្មករចំនួន | ៦៩៦គ្រួសារ |
| - មន្ត្រីរាជការចំនួន | ២៣៥គ្រួសារ |

- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំ មានចំនួន ៧ ៤៧៥ ០០០រៀល។

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក- ទីតាំង

កន្លែងនេសាទសហគមន៍បឹងថ្កាស់ ជាដែននេសាទទឹក ដែលបានលុបចេញពីឡូត៍នេសាទលេខ៥ នៃខេត្តកំពង់ចាម។

កន្លែងនេសាទសហគមន៍បឹងថ្កាស់មានទំហំ៣០៩ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់និងបឹងអន្លង់កណ្ដាល ភូមិជ្រៃក ឃុំបាធាយ ស្រុកបាធាយ
- ខាងត្បូងទល់និងភូមិជាលា និងភូមិបែក៣ាង ឃុំជាលា ស្រុកបាធាយ
- ខាងកើតទល់និងផ្លូវជាតិ៦អា
- ខាងលិចទល់និងភូមិទួល ឃុំបាធាយ ស្រុកបាធាយ។

ខ- ដែននេសាទ

កន្លែងនេសាទសហគមន៍បឹងថ្កាស់មានបឹងចំនួន០៣ មានទំនាបលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹក គឺ៖

- បឹងឃ្លួយ មានទំហំប្រហែល ៣០ហិកតា នេសាទពេញមួយឆ្នាំ
- បឹងថ្កាស់ មានទំហំប្រហែល ១៦ហិកតា នេសាទពេញមួយឆ្នាំ
- បឹងខ្លូ មានទំហំប្រហែល ១៥ហិកតា នេសាទពេញមួយឆ្នាំ
- ទំនាបលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹក មានទំហំប្រហែល២៤៨ហិកតា។

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- អន្លង់បឹងឃ្លួយ មានទំហំ៤,៥ហិកតា (បណ្តោយ៣០០ម៉ែត្រ និងទទឹង១៥០ម៉ែត្រ)។

ឃ- ធនធានជលផល

- ប្រភេទត្រី (ត្រីប្រា ត្រីពោ ត្រីរ៉ស់ ត្រីឆ្តោ ត្រីឆ្លាំង ត្រីកែស ត្រីក្រម៉ម ត្រីតាអោន ត្រីក្អែក ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីឆ្លូញ ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីកញ្ជនជ័យ ត្រីខ្មាន់ ត្រីឈ្មៀត ត្រីកញ្ជ្រូក ត្រីបណ្តូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រាយ ត្រីខ្ទឹង ត្រីព្រួល ត្រីទ្រនេន ត្រីក្រសុក់ ត្រីគល់រាំង ត្រីកន្ទ្រប ត្រីកន្ទ្របខ្លា ត្រីកញ្ចុះ ត្រីលិញ ត្រីក្រាញ់ ត្រីចង្វា ត្រីផ្ទោង ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីឆ្លាំងហាយ ត្រីកន្ធរ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្តាម ត្រីលកសរ ត្រីឆ្អិន ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស់ ត្រីកំភ្លាញ កំពឹស បង្កង,.....។ល។)
- ប្រភេទវារីសត្វ (ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ខ្ចៅ លៀស គ្រំប៉ោក គ្រំចំពុះទា ក្តាម អន្ទង់ កង្កែប អណ្តើក កន្ធាយ កេ,......។ល។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (អញ្ចាញ កន្ត្រែង ស្ពៃងក្របី ដើមរាំង ភ្នំភ្លេង ប្របួយមេ ប្របួយឈ្មោល ថ្លើមអណ្តើក អួយយ៉ាស់(បន្លាយយួន) ស្នួលទឹក ច្រកែង ប្រផេញ ផ្តៅ ក្អែកព្រាប បាក់ដង កន្សៀវ ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្ងាង ត្នួ ខ្ទាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហៃ រញ្ជា ស្នោ ស្លត់ បន្លាឃ្លេ ផ្ទោល ថ្ងាន់ ត្រដក់ កន្ទុយអន្ទង់ ពោះក្អម ត្រកួន ព្រលិតអាចម៍មាន់ ព្រលិតដូង រំចង់ ស្តន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបូង កក់ជ្រូង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ស្តន់ដំរី វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយ កំប្លោក ចក កំពឹងពួយស កំពឹងពួយក្រហម។ល។

## ៤. ការធ្វើនេសាទ

ក- អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២០៧នាក់ ស្រី៥នាក់

- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន២១០នាក់ ស្រី៤នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១៥០នាក់ ស្រី៧នាក់

ខ- ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូករបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៧០ | ១៥០ម-២០០ម/គ្រួសារ | ១៤០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួនអូស | ម៉ែត្រ | ១០ | ១៥-២០ម៉ែត្រ/គ្រួសារ | ២០០ម៉ែត្រ | មករា-ឧសភា |
| សន្ទូចរនង | ផ្លែ | ៥០ | ២០០-៣០០ផ្លែ/គ្រួសារ | ១៥០០០ផ្លែ | សីហា-កុម្ភៈ |
| សន្ទូចបង្កៃ | ផ្លែ | ២០ | ២០០-៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ | សីហា-កុម្ភៈ |
| លបត្រី | គ្រឿង | ១០០ | ៥-៨គ្រឿង/គ្រួសារ | ៨០០គ្រឿង | កក្កដា-វិច្ឆិកា |
| លបកំពីស | គ្រឿង | ២៥ | ៥-១០គ្រឿង/គ្រួសារ | ២៥០គ្រឿង | សីហា-ធ្នូ |
| កន្ទ្រុំកំពីស | គ្រឿង | ៣០ | ១៥-៣០គ្រឿង/គ្រួសារ | ៩០០គ្រឿង | សីហា-ធ្នូ |
| លាន់ | គ្រឿង | ២០ | ២០-៥០គ្រឿង/គ្រួសារ | ១០០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ២០ | ១វង់/គ្រួសារ | ២០វង់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ២០០គ្រួសារ | ២០០-៥០០គីឡូក្រាម | ៦,៥-២៥សេះ |
| ទូកអុំ | ២០គ្រួសារ | ៥០-១០០គីឡូក្រាម | |

- ឧបករណ៍នេសាទ និងទូករបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៣០ | ១៥០ម-២០០ម/គ្រួសារ | ៦០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួនអូស | ម៉ែត្រ | ១៥ | ១៥-២០ម៉ែត្រ/គ្រួសារ | ៣០០ម៉ែត្រ | មករា-ឧសភា |
| សន្ទូចរនង | ផ្លែ | ២០ | ២០០-៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ | សីហា-កុម្ភៈ |
| សន្ទូចបង្កៃ | ផ្លែ | ២៥ | ២០០-៣០០ផ្លែ/គ្រួសារ | ៧៥០០ផ្លែ | សីហា-កុម្ភៈ |
| លបត្រី | គ្រឿង | ៣០ | ៥-៨គ្រឿង/គ្រួសារ | ២៤០គ្រឿង | កក្កដា-វិច្ឆិកា |
| លបកំពីស | គ្រឿង | ២៥ | ៥-១០គ្រឿង/គ្រួសារ | ២៥០គ្រឿង | សីហា-ធ្នូ |
| កន្ទ្រុំកំពីស | គ្រឿង | ១០ | ១៥-៣០គ្រឿង/គ្រួសារ | ៣០០គ្រឿង | សីហា-ធ្នូ |
| លាន់ | គ្រឿង | ១០ | ២០-៥០គ្រឿង/គ្រួសារ | ៥០០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៧ | ១វង់/គ្រួសារ | ៧វង់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ១០០គ្រួសារ | ២០០-៥០០គីឡូក្រាម | ៦,៥-២៥សេះ |
| ទូកអុំ | ៧គ្រួសារ | ៥០-១០០គីឡូក្រាម | |

- ឧបករណ៍នេសាទណនិងទូករបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួន ឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៣០ | ១៥០ម-២០០ម/គ្រួសារ | ៦០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ២៥ | ២០០-៣០០ផ្លែ/គ្រួសារ | ៧៥០០ផ្លែ | សីហា-កុម្ភៈ |
| សន្ទូចបង្កៃ | ផ្លែ | ៣០ | ២០០-៣០០ផ្លែ/គ្រួសារ | ៩០០០ផ្លែ | សីហា-កុម្ភៈ |
| សំណាញ់ | វង់ | ១៥ | ១វង់/គ្រួសារ | ១៥វង់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ១២០គ្រួសារ | ២០០-៥០០គីឡូក្រាម | ៦,៥-២៥សេះ |
| ទូកអុំ | គ្មាន | | |

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ៥៤០គីឡូក្រាម | ១៦២០គីឡូក្រាម | ២១៦០គីឡូក្រាម |
| វារីសត្វ (ខ្យង លៀស) | គ្មាន | | |

## ៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក- ទស្សនៈវិស័យ

សហគមន៍នេសាទបឹងថ្កាស់ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ- គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ដែលបានលុបចេញពីឡូតិ៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋ ធ្វើនេសាទជាប្រពៃណី ទំនាបលិចទឹកក្នុងរដូវតំឡើង និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ប្រភេទឧបករណ៍អនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| ១.បឹងឃ្លួយ | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ១២០០០ម៉ែត្រ/ ៦០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ៤០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មករា-ឧសភា | អួនអូស | ១៥ម/គ្រួសារ | ២៤០ម៉ែត្រ/ ១៦គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | សីហា-កុម្ភៈ | សន្ទូចរនង | ៣០០ផ្លែ/គ្រួសារ | ១២០០០ផ្លែ/ ៤០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | សីហា-កុម្ភៈ | សន្ទូចបង្កៃ | ៣០០ផ្លែ/គ្រួសារ | ១២០០០ផ្លែ/ ៤០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | កក្កដា-វិច្ឆិកា | លបត្រី | ៦គ្រឿង/គ្រួសារ | ១២០គ្រឿង/ ២០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | សីហា-ធ្នូ | លបកំពឹស | ៨គ្រឿង/គ្រួសារ | ១២៨គ្រឿង/ ១៦គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | សីហា-ធ្នូ | កន្ទ្រុំកំពឹស | ៣០គ្រឿង/គ្រួសារ | ១២០០គ្រឿង/ ៤០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លាន់ | ៤០គ្រឿង/គ្រួសារ | ៨០០គ្រឿង/ ២០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| ២.បឹងថ្កាស់ | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ៣០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៣០០០ម៉ែត្រ/ ២០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មករា-ឧសភា | អួនអូស | ១៥ម/គ្រួសារ | ១២០ម៉ែត្រ/ ៨គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |

| | | | | |
|---|---|---|---|---|
| | សីហា-កុម្ភៈ | សន្ទូចរនង | ៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | សីហា-កុម្ភៈ | សន្ទូចបង្កៃ | ៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-វិច្ឆិកា | លបត្រី | ៦គ្រឿង/គ្រួសារ | ៦០គ្រឿង/<br>១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | សីហា-ធ្នូ | លបកំពឹស | ៨គ្រឿង/គ្រួសារ | ៦៤គ្រឿង/<br>៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | សីហា-ធ្នូ | កន្ទ្រុំកំពឹស | ៣០គ្រឿង/គ្រួសារ | ៦០០គ្រឿង/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លាន់ | ៤០គ្រឿង/គ្រួសារ | ៤០០គ្រឿង/<br>១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៣.បឹងខ្លួ | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៦០០០ម៉ែត្រ/<br>៣០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៣០០០ម៉ែត្រ/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មករា-ឧសភា | អួនអូស | ១៥ម/គ្រួសារ | ១២០ម៉ែត្រ/<br>៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | សីហា-កុម្ភៈ | សន្ទូចរនង | ៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | សីហា-កុម្ភៈ | សន្ទូចបង្កៃ | ៣០០ផ្លែ/គ្រួសារ | ៦០០០ផ្លែ/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-វិច្ឆិកា | លបត្រី | ៦គ្រឿង/គ្រួសារ | ៦០គ្រឿង/<br>១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | សីហា-ធ្នូ | លបកំពឹស | ៨គ្រឿង/គ្រួសារ | ៦៤គ្រឿង/<br>៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | សីហា-ធ្នូ | កន្ទ្រុំកំពឹស | ៣០គ្រឿង/គ្រួសារ | ៦០០គ្រឿង/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លាន់ | ៤០គ្រឿង/គ្រួសារ | ៤០០គ្រឿង/<br>១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

គ២-ផែនការបោះបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍

ផែនការបោះបង្គោលព្រំប្រទល់កន្លែងនេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែន នេសាទ | ទំហំ (ហិកតា) | សកម្មភាព | ប៉ាន់ស្មានតម្លៃ (ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងនេសាទ សហគមន៍បឹងថ្កាស់ | ៣០៩ | - ផ្សព្វផ្សាយអំពីការបោះបង្គោលព្រំប្រទល់ទៅតាមនិយាមកាចំនួន១២ចំណុចនៃដែនទីកន្លែងនេសាទសហគមន៍បឹងថ្កាស់<br>- បោះបង្គោលថ្មចំនួន១២ដើម | ២០០០ | ១/៣/១៩ | ១/៤/២១ |

គ៣-ផែនការកែលំអដែននេសាទ

ផែនការការលំអដែននេសាទ ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែន នេសាទ | ទំហំ (ហិកតា) | ទំហំ ដែល ត្រូវកែលំអ | សកម្មភាព | ប៉ាន់ស្មាន តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងថ្កាស់ | ១៦ | ៦ហិកតា (៣០០មx ២០០ម) | ជីកកាយយកដីល្បាប់ស្រទាប់បាតបឹងឲ្យមានជម្រៅទឹកប្រហែល២,៥ - ៣ម៉ែត្រក្នុងរដូវប្រាំង | ១៥០០០ | ១/៣/១៩ | ១/៤/២១ |

គ៤-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែន នេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃ ការអភិរក្ស | សកម្មភាព | ប៉ាន់ស្មាន តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងឃ្លួយ (៣០ហ.ត) | ៤,៥ហិកតា (ប=៣០០ម x ទ=១៥០ម) | អភិរក្សត្រីមេពូជ | បោះបង្គោលស៊ីម៉ងត៏ (7mX0.15mx0.15m) ចំនួន១៨ដើមព័ទ្ធជុំវិញកន្លែងអភិរក្សក្នុងចន្លោះ៥០ម៉ែត្របោះ១បង្គោល | ១៨០០ | ១/៣/១៩ | ១/៥/២១ |
| | | | ធ្វើស្លាកសញ្ញាអភិរក្សត្រីមេពូជចំនួន៨ផ្ទាំង | ៤០០ | ១/៤/១៩ | ១/៦/២១ |
| | | | ទម្លាក់គល់ឈើ២៥០គល់ចូលក្នុងកន្លែងអភិរក្ស | ៣៧៥០ | ១/៣/១៩ | ១/៥/២១ |
| | | | សង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | ២០០០ | ១/៥/១៩ | ១/៧/២១ |

គ៥-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល

ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | គោលបំណង | អ្នកចូលរួមអនុវត្តន៍ | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទិញទូកស្នាច់០២គ្រឿង ប្រវែង៩ម៉ែត្រនិងម៉ាស៊ីនទូកកម្លាំង១៨សេះ | ចុះល្បាតការពារនិងទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | គណកម្មការ និងក្រុមល្បាតសហគមន៍នេសាទ | ២៥០០ | ២០១៩ | ២០២១ |
| ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត( អាវពោងសុវត្ថិភាព អាគុយ អំពូលភ្លើងហ្វា ទូរស័ព្ទ វិទ្យុទាក់ទង ម៉ាស៊ីនថតពិលអាវភ្លៀង កែវយឹត មេក្រូ ប្រេងសាំង ប្រេងម៉ាស៊ីន..។ល។ | ប្រើប្រាស់សម្រាប់ចុះល្បាត តាមដាន ត្រួតពិនិត្យ ទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទនេសាទ | | ១៥០០ | ២០១៩ | ២០២១ |
| រៀបចំក្រុមល្បាតនិងបែងចែកតាមវេនចុះល្បាតប្រចាំថ្ងៃនិងប្រចាំសប្តាហ៍ | ឲ្យមានក្រុម និងវេនចុះល្បាតឲ្យបានទៀងទាត់ជាប្រចាំ | | ១០០០ | ២០១៩ | ២០២១ |
| -ផ្សព្វផ្សាយតាមមេក្រូ ៦ដង/ឆ្នាំ<br>-បិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយ ចំនួន២ដង/ឆ្នាំ | បង្កើនការយល់ដឹងអំពីឧបករណ៍នេសាទស្របច្បាប់ ឧបករណ៍នេសាទហាមឃាត់ និងការពារកន្លែងអភិរក្សត្រីមេពូជ | - គណកម្មការ និងក្រុមល្បាតសហគមន៍<br>- អាជ្ញាធរភូមិ ឃុំ | ៥០០ | ២០១៩ | ២០២១ |

គ៦-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំឡើង ដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួនគ្រួសារ | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងស្រះ | ១០០ | ប្រា ក្រាញ់ ទីឡាព្យា | ៨០០០០០កូនត្រី | ១/២/១៩ | ១/៦/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៣០០ | ត្រីអណ្តែង | ១៦៨០០០កូនត្រី | ១/៤/១៩ | ១/៦/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ២០០ | កង្កែប | ១៦០០០០កូនកង្កែប | ១/៤/១៩ | ១/៨/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ១០០ | អន្ទង់ | ៥៦០០០កូនអន្ទង់ | ១/១/១៩ | ១/១០/២១ |

## គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ

ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| វគ្គបណ្តុះបណ្តាល និងទិវាអភិរក្ស | គោលបំណង | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ក. វគ្គបណ្តុះបណ្តាល | | | | |
| ច្បាប់ស្តីពីជលផល អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងស.ន | បង្កើនយល់ដឹងអំពីខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលជលផល | | ២០១៩ | ២០២១ |
| ជំនាញសម្របសម្រួល និងជំនាញដោះស្រាយទំនាស់ | មានចំណេះដឹងក្លាយជាអ្នកសម្របសម្រួល និងចេះដោះស្រាយទំនាស់បានល្អ | | ២០១៩ | ២០២១ |
| របៀបសរសេរលិខិតរដ្ឋបាល(របាយការណ៍ និងកំណត់ហេតុ) | មានចំណេះដឹងអំពីសរសេរ និងគ្រប់គ្រងលិខិតរដ្ឋបាល | | ២០១៩ | ២០២១ |
| របៀបរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងធ្វើផែនការអនុវត្តន៍សកម្មភាពគម្រោង | មានចំណេះដឹងអំពីរបៀបធ្វើផែនការសហគមន៍ និងផែនអនុវត្តន៍សកម្មភាពគម្រោង | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| របៀបសរសេរគម្រោងស្នើសុំថវិកា និងធ្វើផែនការគ្រប់គ្រងថវិកាស.ន និងរបៀបស្វែងរកថវិកា | មានចំណេះដឹងអំពីរបៀបសរសេរគម្រោងស្នើសុំថវិកា និងការធ្វើផែនការគ្រប់គ្រង និងយុទ្ធសាស្ត្រស្វែងរកថវិកា | | ២០១៩ | ២០២១ |
| - កសាងភាពជាដៃគូ និងបណ្តាញ<br>- ភាពជាអ្នកដឹកនាំ | -មានចំណេះដឹងអំពីសារៈប្រយោជន៍កសាងភាពជាដៃគូ និងបណ្តាញ<br>-ក្លាយទៅជាអ្នកដឹកនាំស.នល្អ | | ២០១៩ | ២០២១ |
| ប្រភេទនៃអ្នកចូលរួមក្នុងការអភិវឌ្ឍ | មានចំណេះដឹងអំពីការជ្រើសរើស និងធ្វើការជាមួយអ្នកចូលរួមពិតប្រាកដក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋាន | | ២០១៩ | ២០២១ |
| ខ. ទិវាអភិរក្ស និងផ្សព្វផ្សាយ | | | | |
| ការបង្កើត និងសារប្រយោជន៍នៃការគ្រប់គ្រងកន្លែងអភិរក្សត្រីមេពូជ | ឲ្យមានការចូលរួមពីសមាជិកស.ន និងពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈសំណួរ ចម្លើយ ល្បែងប្រាជ្ញា ផ្សព្វផ្សាយអំពីការបង្កើត និងសារៈប្រយោជន៍កន្លែងអភិរក្ស | -គណកម្មការស.ន<br>-សមាជិកសហគមន៍នេសាទ<br>-មិនមែនសមាជិកសហគមន៍ | ២០១៩ | ២០២១ |

| | | | | |
|---|---|---|---|---|
| គុណតម្លៃនៃព្រៃលិចទឹក និងការគ្រប់គ្រងព្រៃលិចទឹក | ឲ្យមានការចូលរួមពីសមាជិក ស.ន និងពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈសំណួរ ចម្លើយ ល្បែងប្រាជ្ញា ផ្សព្វផ្សាយអំពីគុណតម្លៃ និងការ គ្រប់គ្រងព្រៃលិចទឹក | -អាជ្ញាធរភូមិ ឃុំ<br>-ពលរដ្ឋទូទៅ | ២០១៩ | ២០២១ |
| ការធ្វើនេសាទប្រកបដោយនិរន្តរភាពក្នុងកន្លែងនេសាទសហគមន៍ | ឲ្យឲ្យមានការចូលរួមពីសមាជិក ស.ន និងពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈសំណួរ ចម្លើយ ល្បែងប្រាជ្ញា ផ្សព្វផ្សាយអំពីការធ្វើនេសាទប្រកបដោយនិរន្តរភាព | | ២០១៩ | ២០២១ |
| ផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈសំណួរ ចម្លើយ ល្បែងប្រាជ្ញា ផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍ | | ២០១៩ | ២០២១ |

គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកសហគមន៍នេសាទ<br>-រៀបចំបញ្ជីគណនេយ្យ<br>-ប្រមូលប្រាក់ភាគទានសុំចូលជាសមាជិកស.នចាស់ និងថ្មី | ១/១/១៩ | ១/១/២១ | ១២៥ | ១០០០៛/១នាក់ សមាជិកចាស់/ថ្មី អាច៥០០នាក់ រយៈពេល៣ឆ្នាំ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយអំពីការបង់<br>-ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ | ១/១/១៩ | ១/១/២១ | ១៥០០ | -២០០០០៛ ៖សមាជិកធ្វើនេសាទជាអាជីព<br>-៥០០០៛ ៖សមាជិកធ្វើនេសាទម្តងម្កាល<br>-១០០០៛ ៖ ចំពោះសមាជិកគាំទ្រមិនធ្វើនេសាទ<br>-[illegible] ៖ មិនមែនជាសមាជិកស.នតែធ្វើនេសាទជាអាជីព |

| | | | | | |
|---|---|---|---|---|---|
| -ជំនួយសប្បុរសជន<br>-អង្គការនានា<br>-ជំនួយរាជរដ្ឋាភិបាល | -រៀបចំសរសេរគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-ធ្វើគម្រោងផែនការស.នសុំដាក់បញ្ចូលសមាហរកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ១/១/១៩ | ១/១/២១ | ៤៦៤៥០ | ១៥៤៨៤ដុល្លារ/ឆ្នាំ |
| | | | គម្រោងថវិកាសរុប | ៤៨០៧៥$ | រយៈពេល៣ឆ្នាំ |

ឃ- ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកស្វែងថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូអភិវឌ្ឍន៍សម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសម្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងថ្កាស់ រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំពិគ្រោះយោបល់អំពីការប្រើប្រាស់ឧបករណ៍នេសាទឲ្យសមស្រប និងកំណត់ទីកន្លែងនេសាទ | -ធ្វើនេសាទប្រកបដោយនិរន្តរភាព<br>-បង្កើនប្រាក់ចំណូលពីផលនេសាទ<br>-ធនធានជលផលកើនឡើង | ៥០០០ | -រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផល ឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ២០១៩ | ២០២១ | |
| គ២-ផែនការបោះបង្គោលព្រំប្រទល់កន្លែងនេសាទ | -ផ្សព្វផ្សាយអំពីការបោះបង្គោលព្រំប្រទល់ទៅតាមនិយាមកានៃផែនទី<br>-បោះបង្គោលព្រំប្រទល់ចំនួន១២បង្គោលថ្ម | មានបង្គោលកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍បឹងថ្កាស់ច្បាស់លាស់ | ២០០០ | | ២០១៩ | ២០២១ | |
| គ៣-ផែនការកែលំអដែននេសាទ | ជីកកាយយកដីល្បាប់ស្រទាប់បាតបឹងថ្កាស់ឲ្យបានជម្រៅទឹក២,៥-៣ម៉ែត្រក្នុងរដូវប្រាំង | បឹងថ្កាស់នឹងមានជម្រៅទឹកសមស្រប ដែលអាចឲ្យផលស្តុកត្រីកើនឡើង | ១៥០០០ | | ២០១៩ | ២០២១ | |
| គ៤-ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | បោះបង្គោលស៊ីម៉ងត៍ចំនួន១៨ដើមដាក់ព័ទ្ធជុំវិញកន្លែងអភិរក្សទំហំ (300មX150ម) | -មានព្រំប្រទល់កន្លែងអភិរក្ស<br>-បែងចែកបានច្បាស់រវាងកន្លែងនេសាទ និងកន្លែងអភិរក្សត្រីមេពូជ | ១៨០០ | | ២០១៩ | ២០២១ | |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៤ផ្ទាំងដាក់នៅជាប់ព្រំប្រទល់កន្លែងអភិរក្ស | មានសញ្ញាសម្គាល់ហាមឃាត់ចូលនេសាទ និងបើកបរទូកឆ្លងកាត់ខាងក្នុងកន្លែងអភិរក្ស | ៤០០ | | ២០១៩ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ទម្លាក់គល់ឈើចំនួន ២៥០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | មានជម្រកសប្បនិម្មិតត្រីមេពូជសម្រាប់រស់នៅ បន្តពូជ ពងកូន និងការពារមិនលួចនេសាទ | ៣៧៥០ | | ២០១៩ | ២០២១ | |
| | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | មានស្នាក់ការបណ្តែតទឹកសម្រាប់យាមល្បាតការពារមិនឲ្យចូលនេសាទក្នុងកន្លែងអភិរក្សត្រីមេពូជ និងទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ | ២០០០ | | ២០១៩ | ២០២១ | |
| គ៥-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | -ទិញទូកស្ទាច់០២គ្រឿង ប្រវែង៩ម៉ែត្រ និងម៉ាស៊ីនទូកកម្លាំង១៨សេះ<br>-ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត<br>-រៀបចំក្រុមចុះល្បាត<br>-ផ្សព្វផ្សាយតាមមេក្រុ៦ដងក្នុងមួយឆ្នាំ និងប៊ិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយ២ដងក្នុង១ឆ្នាំ | -មានទូកម៉ាស៊ីន និងឧបករណ៍សម្ភារៈសម្រាប់ចុះល្បាតទប់ស្កាត់បទល្មើស<br>-ប្រជានេសាទទូទៅ និងសមាជិកសហគមន៍នេសាទបានយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍នេសាទស្របច្បាប់នៅក្នុងកន្លែងសហគមន៍នេសាទ និងបទល្មើសនេសាទថយចុះ | ៥៥០០ | | ២០១៩ | ២០២១ | |
| គ៦-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | -បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមត្រី កង្កែប អន្ទង់ជាលក្ខណៈពាណិជ្ជកម្មនៅក្នុងស្រះ បែ និងគង់កៅស៊ូ។ | សមាជិកសហគមន៍នេសាទចំនួនប្រហែល២០០គ្រួសារមានចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រី កង្កែប អន្ទង់លក្ខណៈពាណិជ្ជកម្មនៅក្នុងស្រះ បែ និងគង់កៅស៊ូ។ | ៨០០០ | | ២០១៩ | ២០២១ | |
| គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | -បណ្តុះបណ្តាលអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសហគមន៍ | - គណកម្មការ និងសមាជិកសហគមន៍បានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសហ- | ៣០០០ | | ២០១៩ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | នៃសាទ និងពង្រឹងសមត្ថភាពគណៈកម្មការ និងសមាជិកសហគមន៍<br>-ធ្វើទិវាអភិរក្ស និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ និងលេងល្បែងប្រាជ្ញា ដែលទាក់ទងកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍ | គមន៍នៃសាទ និងមានសមត្ថភាពក្លាយជាអ្នកដឹកនាំល្អ ឬជាគ្រូបង្គោលក្នុងសហគមន៍មូលដ្ឋាន<br>- សមាជិកសហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីសារប្រយោជន៍នៃកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នៃសាទ។ | | | | | |
| គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នៃសាទ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកសហគមន៍<br>-ប្រមូលការបង់ប្រាក់ភាគទានសុំចូលជាសមាជិក ស.ន និងអ្នកសុំចូលថ្មី<br>-ធ្វើគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-យកផែនការនេះ សុំដាក់បញ្ចូលសមារហកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ទទួលបានថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍តាមគម្រោងផែនការ | ៤៨០៧៥ | -សមាជិក និងមិនមែនសមាជិកសហគមន៍នៃសាទ<br>-រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផល ឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នៃសាទ<br>-សប្បុរសជន | ១/១/១៩ | ១/១/២១ | |

## តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | | | | | | | ២០២០ | | | ២០២១ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ... | ធ្នូ | មករា | ... | ធ្នូ |
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| គ២-ផែនការបោះបង្គោលព្រំប្រទល់កន្លែងនេសាទ | | — | — | — | — | → | | | | | | | — | → | | — | → | |
| គ៣-ផែនការកែលំអដែននេសាទ | | — | — | → | | | | | | | | | → | | | → | | |
| គ៤-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | — | — | — | — | → | | | | | | — | → | | | | |
| គ៥-ផែនការល្បាតទប់ស្កាត់បទល្មើសផលផល | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| គ៦-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | — | — | — | — | — | — | — | — | — | → | - - - | - - - | - - → | - - → |
| គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |

សូមគោរពជូន
លោកមេឃុំជាលា និងឃុំបាធាយ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.................. ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
.................. ថ្ងៃទី.......ខែ.......ឆ្នាំ២០១៨
ប្រធានគណៈកម្មការសហគមន៍នេសាទបឹងថ្កាស់

លេខ :..........
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកងមាស
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.................. ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
.................. ថ្ងៃទី.......ខែ.......ឆ្នាំ២០១៨
មេឃុំជាលា
គុជ ឈឿន

លេខ :..........
ថ្ងៃ.................. ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
.................. ថ្ងៃទី.......ខែ.......ឆ្នាំ២០១៨
មេឃុំបាធាយ
ឃុត ឃឹម

លេខ :..........

បានឃើញ និងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

កំពង់ចាម ថ្ងៃទី..... ខែ.....ឆ្នាំ២០១៨

នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម

អ៊ុក_ណារិន

លេខ :..........

បានឃើញ និងឯកភាព

ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

កំពង់ចាម ថ្ងៃទី..... ខែ.....ឆ្នាំ២០១៨

**នាយផ្នែករដ្ឋបាលជលផលកងមាស**

លេខ :..........

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

កំពង់ចាម ថ្ងៃទី ១១ ខែ.....ឆ្នាំ២០១៨

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម**